| | | | | | | | |
|---|---|---|---|---|---|---|---|
| បញ្ចប់ | ១ |  ៣ | ២ | ១ |  ១ | ១ | ៣ |
|  ២ | ២ | ១ | ២ | ៣ | ១ |  ២ | ១ |
| ៣ |  ១ | ១ | ៣ |  ៣ | ២ | ៣ | ៣ |
| ៣ | ២ |  ១ | ១ | ៣ |  ២ | ៣ | ២ |
| ២ |  ១ | ២ | ៣ | ២ |  ២ | ១ | ២ |
| ចាប់ផ្តើម | ២ | ១ | ១ | ២ | ១ | ១ | ២ |

# ល្បែងប្រមូលសំរាម

សកម្មភាព៖

ចិត្តចលភាព ៖ បំណិនចលនាតូច៖ ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក
វិទ្យាសាស្ត្រ ៖ បំណិនអនាម័យ ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម
សិក្សាសង្គម ៖ បំណិនក្នុងសង្គម ៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ
បុរេគណិត ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ
ទំហំនិងពណ៌ ៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ
ភាសាខ្មែរ ៖ ការប្រើពាក្យតាមវេយ្យាករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ

គោលបំណង ៖

ចិត្តចលភាព ៖ បំណិនសម្បទា ៖ កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។
វិទ្យាសាស្ត្រ ៖ បំណិនសម្បទា ៖ ចោលសំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ
សិក្សាសង្គម ៖ បំណិនសម្បទា ៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។
បុរេគណិត ៖ បំណិនសម្បទា ៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។ បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។
ភាសាខ្មែរ ៖ វិជ្ជាសម្បទា ៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។
រយៈពេល ៖ ៣០ នាទី
ឧបករណ៍ ៖ ក្តារល្បែងដែលមានពណ៌ច្រើន១សន្លឹកក្នុង១ក្រុម គ្រាប់ឡុកឡាក់ចំនួន១សម្រាប់១ក្រុម កាតធុងសំរាម៥ប្រភេទ៥ពណ៌ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង ៣.ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទីក និង ៥. ពណ៌ក្រហមសំណល់គ្រោះថ្នាក់ ) និងគម្របដបមួយចំនួន (១០ក្នុងធុងសំរាម១)។
ការរៀបចំ ៖ ត្រៀមសម្ភារឱ្យបានគ្រប់គ្រាន់ ក្នុងការលេងល្បែងមួយនេះ ដូចជារៀបចំបែងចែកសមាជិកតាមក្រុមនីមួយៗ ដែលអាចមានត្រឹមតែ៤ ទៅ៥នាក់ក្នុងមួយក្រុមបាន។

សេចក្តីណែនាំ៖

១.ចែកកុមារជាក្រុមដែលមានសមាជិក៤ទៅ៥នាក់ក្នុងមួយក្រុម។
២.ចែកសម្ភារក្នុងការលេងល្បែងនេះមួយក្រុម១ឈុត ដែលមានដូចជា ក្តារល្បែងដែលមានពណ៌ច្រើន១សន្លឹកក្នុង១ក្រុម គ្រាប់ឡុកឡាក់ចំនួន១សម្រាប់១ក្រុម កាតធុងសំរាម៥ប្រភេទ៥ពណ៌ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង ៣.ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទីក និង ៥. ពណ៌ក្រហមសំណល់គ្រោះថ្នាក់ ) និងគម្របដបមួយចំនួន (១០ក្នុងធុងសំរាម១)។
៣.នៅពេលដែលចែករួចរាល់ហើយ ចាប់ផ្តើមលេង។ ដោយក្នុងក្រុមត្រូវរកអ្នកដែលអាចចាប់ផ្តើមលេងមុន ដោយវិធីសាស្ត្រផ្សេងៗគ្នា បែបណាក៏បានដែរ។
៤.ក្មេងដែលលេងមុន ត្រូវបោះគ្រាប់ឡុកឡាក់ចំនួន បើបានចំនួនប៉ុន្មាន ត្រូវដើរលើក្តារល្បែងតាមចំនួនហ្នឹង និងតាមសញ្ញាព្រួញដែរ។
៥.ប្រសិនបើកុមារដើរចំប្រអប់ដែលមានពណ៌ដូចនឹងធុងសំរាមដែលបានតំរៀបខាងលើ កុមារត្រូវនិយាយប្រាប់ថាជាប្រភេទសំណល់អ្វីជាមុនសិន និង ត្រូវយកគម្របដបពីកន្លែងធុងសំរាមនោះតាមចំនួននៅក្នុងប្រអប់ហ្នឹងដែរ (បើ១យក១ បើ២យក២ មាន៣យក៣)។
៦.និងមានករណីមួយចំនួនទៀត ដែលត្រូវធ្វើ ប្រសិនបើដើរចំប្រអប់ដែលពណ៌សដែលមានរូបសំរាម និងមានចំនួននៅក្នុងហ្នឹងដែរ។ កុមារត្រូវដកគម្របដបរបស់ខ្លួនដែលមានស្រាប់ ទៅតាមចំនួនដែលមានក្នុងប្រអប់ហ្នឹង ទៅដាក់នៅក្នុងធុងសំរាមដែលជាប្រភេទត្រូវនឹងរូបភាពសំរាមហ្នឹង។
ឧ. បើគាត់ដើរចំប្រអប់ពណ៌សដែលមានរូបភាពសំរាម សំបកចេក (ជាប្រភេទសំណល់ផ្ទះបាយ) ក្មេងនោះ ត្រូវដកគម្របដបរបស់ខ្លួនតាមចំនួនដែលមានក្នុងប្រអប់ ទៅដាក់ក្នុងធុងសំរាមសំណល់ផ្ទះបាយ ជាការស្រេច។
៧.លេងបែបនេះរហូតដល់មានកុមារណាម្នាក់ដើរដល់ប្រអប់ថា បញ្ចប់ គឺល្បែងត្រូវបានចប់ គ្រប់គ្នាត្រូវរាប់គម្របដបដែលម្នាក់ៗមាន ថាតើអ្នកណាបានច្រើនជាងគេ គឺជាអ្នកឈ្នះទី១ និងទី២ បន្តបន្ទាប់គ្នាជាការស្រេច។ បន្ទាប់ប្រាប់ឱ្យកុមារជួយប្រមូល និងរៀបចំសម្ភារលេងទុក ឱ្យបានត្រឹមត្រូវជាការស្រេចតែម្តង។

★ ការលេងល្បែងនេះ អាចឱ្យកុមារបានស្គាល់ច្រើន ទាំងស្គាល់ពណ៌ ស្គាល់ចំនួន ស្គាល់សំរាម ការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងផ្សេងៗទៀតផងដែរ។






















៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២

៥
៦ ៣ ១ ៤
២



សំណល់កំប៉ុង




សំណល់ផ្ទះបាយ




សំណល់ប្លាស្ទិក




សំណល់គ្រោះថ្នាក់




សំណល់ក្រដាស


